ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ.......................ន. គ. ស .......

ថ្ងៃចន្ទ ១៣កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កុម្ភៈ គ.ស.២០២៥

# សេចក្តីជូនដំណឹងសាឡើងវិញ
# ស្តីពី
# ការជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថាន
# ដើម្បីបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs)

**និយ័តករគណនេយ្យនិងសវនកម្ម** (**ន.គ.ស.**) គឺជាស្ថាប័ននិយ័តកម្មតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ច របស់ខ្លួន ន.គ.ស. បានដាក់ចេញនូវផែនការបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនធំ សហគ្រាសធុនតូច និងមធ្យម អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីបញ្ជ្រាបការយល់ដឹងលើស្តង់ដាគណនេយ្យឱ្យបានទូលំទូលាយទាំងការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មស្របតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដែលនឹងត្រូវធ្វើឡើងដោយក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលមានជំនាញវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដែលមានគុណវុឌ្ឍិខ្ពស់លើវិស័យគណនេយ្យនិងសវនកម្ម។

ក្នុងន័យនេះ **ន.គ.ស.** សូមប្រកាសជ្រើសរើសក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលមានគុណវុឌ្ឍិដូចខាងក្រោម៖

## ១. លក្ខខណ្ឌគុណវុឌ្ឍិ

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល៖

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មពេញលេញ
- មានចំណេះដឹងអំពីស្តង់ដាគណនេយ្យ និងសវនកម្មដែលបានដាក់ឱ្យអនុវត្តជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានបទពិសោធន៍បណ្តុះបណ្តាលក្នុងវិស័យគណនេយ្យ និងសវនកម្មរយៈពេលយ៉ាងតិច៥ឆ្នាំ
- ធ្លាប់បានចូលរួមក្នុងការអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

## ២. សមិទ្ធផលដែលត្រូវផ្តល់

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលដែលទទួលជោគជ័យក្នុងការដេញថ្លៃ ត្រូវផ្តល់ជូន **ន.គ.ស.** នូវការបណ្តុះបណ្តាលស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ជូនដល់សិក្ខាកាមដែលកំណត់ដោយ **ន.គ.ស.** បានគ្រប់ចំនួន និងទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពខ្ពស់ដោយភ្ជាប់បង្ហាញជាមួយនូវរបាយការណ៍ការបណ្តុះបណ្តាល។

## ៣. កម្រៃ

កម្រៃសម្រាប់ការបណ្តុះបណ្តាល គឺបើកចំហរសម្រាប់ការចរចារ។

## ៤. រយៈពេលសម្រាប់ការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលស្តង់ដាគណនេយ្យខាងលើនេះមានរយៈពេលមួយឆ្នាំគិតចាប់ពីថ្ងៃចុះកិច្ចសន្យា។ ក្នុងករណីមានការបន្ត ឬពន្យារពេលក្នុងបណ្តុះបណ្តាល នឹងត្រូវមានការពិភាក្សា និងចរចារ។

កិច្ចសន្យានៃការផ្តល់សេវាបណ្តុះបណ្តាលនឹងត្រូវបង្កើតឡើងរវាង **ន.គ.ស.** ជាមួយនឹងក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាល ដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

## ៥. ការដាក់ពាក្យ

ក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាលមានចំណាប់អារម្មណ៍ សូមផ្ញើសេចក្តីចំណាប់អារម្មណ៍មក **ន.គ.ស.** តាមរយៈអ៊ីម៉ែល t.satya@acar.gov.kh និង h.sokunthea@acar.gov.kh ឱ្យបានត្រឹម ថ្ងៃទី២៤ ខែកុម្ភៈឆ្នាំ២០២៥ ដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

ចំពោះក្រុមហ៊ុន ឬវិទ្យាស្ថានបណ្តុះបណ្តាល ដែលបានជាប់ក្នុងបញ្ជីសម្រាំងនឹងត្រូវបានជូនដំណឹង។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង និងតេឡេក្រាម ៖ ០៦៩ ៧៨៣ ៩៣៦៨ / ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**